# តើអង្គការខារ៉ាមកម្ពុជាជាអ្វី?

អង្គការខារ៉ាមកម្ពុជាជាអង្គការក្រៅរដ្ឋាភិបាលមួយ បានចាប់បដិសន្ធិ ឡើងនៅឆ្នាំ២០០០ ដោយធ្វើការងារផ្តោតទៅលើស្ត្រីចំណាកស្រុក ជនជាតិវៀតណាម និងកម្ពុជាដែលកំពុងបំរើការងារនៅតាមសេវាកំសាន្តនានា ក្នុងប្រទេសកម្ពុជា ព្រមទាំងពលករចំណាកស្រុកកម្ពុជា ដែលត្រៀមខ្លួនទៅបំរើការងារនៅក្រៅប្រទេស។ ការងារសំខាន់ៗ របស់អង្គការខារ៉ាម រួមមានការ ធ្វើមាតុភូមិនិវត្តន៏ និងសមាហរណកម្មជនរងគ្រោះដោយការជួញដូរ និងការកេងប្រវ័ញ្ចកំលាំងការងារទៅតាមសហគមន៏ និង ការចុះអប់រំផ្ទាល់តាមសហគមន៏ ទៅដល់ស្ត្រីចំណាកស្រុកវៀតណាម និងកម្ពុជាដែលបំរើការងារនៅតាមសេវាកំសាន្តនានា ស្តីអំពី សុខភាពបន្តពូជ សិទ្ធិមនុស្ស និង ផ្តល់វគ្គបណ្តុះបណ្តាលដល់ពលករចំណាកស្រុកកម្ពុជា មុនពេលចាកចេញដំណើរទៅធ្វើការនៅបរទេស ព្រមទំាងធ្វើការងារទាក់ទាញមតិគាំទ្រ។

## ទស្សនៈវិស័យ

មនុស្សគ្រប់រូបមានសិទ្ធិក្នុងការស្នាក់នៅ ឬធ្វើដំណើរ រស់នៅ និង ធ្វើការងារក្នុងភាពថ្លៃថ្នូរ ដោយមានសិទ្ធិស្មើរគ្នានៅក្នុងសង្គម ដែលគុណភាពនៃជីវិតរបស់ពួកគេត្រូវបានធានា។

## បេសកកម្ម

- ផ្តល់សិទ្ធិអំណាចដល់ជនចំណាកស្រុក ក្រុមគ្រួសារ និង សហគមន៏របស់ពួកគេ ដើម្បីលើកកម្ពស់ និងការពារសិទ្ធិមនុស្ស រួមទាំងសិទ្ធិខាងសុខភាពបន្តពូជ និងសិទ្ធិខាងផ្លូវភេទ តាមរយៈវដ្តនៃចំណាកស្រុក។

- បង្កើនន្ទូវចំណេះដឹងតាមរយៈសកម្មភាពស្រាវជ្រាវទៅលើភាពងាយរងគ្រោះ និងស្ថានភាពសុខភាពរបស់ជនចំណាកស្រុក ដើម្បីបង្កើតន្ទូវផែនការសំរាប់អនុវត្តន៏ និងអន្តរាគមន៏ឱ្យមានប្រសិទ្ធិភាពទៅលើការងារទាក់ទាញការគាំទ្រមតិ និងការងារថ្នាក់តំបន់។

- បញ្ចូលបញ្ហាការងារចំណាកស្រុក និងអេដស៏របស់ជនចំណាកស្រុក ដើម្បីកំណត់ន្ទូវបទអន្តរាគមនៅក្នុងគោលនយោបាយ និងការអភិវឌ្ឍន៏កម្មវិធី។

- ទាក់ទាញការគាំទ្រមតិដើម្បីឱ្យមានភាពប្រសើរឡើងនៃគុណភាពជីវិតរបស់ជនចំណាកស្រុក រួមទាំងលទ្ធភាពទទួលបានសេវាសុខភាព ការថែទាំឱ្យបានត្រឹមត្រូវស្មើភាពគ្នា។

- លើកកំពស់សមភាពយេនឌ័រ និងភាពយុត្តិធមិ។

# អង្គការខារ៉ាមកម្ពុជា


**ផ្ទះលេខ១៩៣អាអឺសៀ្វ សង្កាត់បឹងកេងកង១ ខ័ណ្ឌចំការមន ក្រុងភ្នំពេញ ទូរស័ព្ទ និងទូរសារលេខ (៨៥៥) ២៣ ២១៨ ០៦៥ អ៊ីមែល caram.cam@online.com.kh ប្រអប់សំបុត្រ ២៦២៥ ភ្នំពេញ៣ កម្ពុជា។**


---

ប្រសិនបើលោកអ្នក ប្អូនៗ និងស្ត្រីពលករចំណាកស្រុកមានបញ្ហាត្រូវគេវាយធ្វើបាប រំលោភបំពាន បៀតបៀនលើរាងកាយ ឬត្រូវការជួយក្នុងករណីបន្ទាន់ សូមទំនាក់ទំនងមក **អង្គការខារ៉ាមកម្ពុជា** តាម

☞ ទូរស័ព្ទលេខ : ០២៣ ២១៨ ០៦៥/០១២ ៩៦១ ៤២៧/ ០៨៩ ២៦១ ២១០/០១២ ៩៤៩ ៩១៤

# កម្មវិធីសំខាន់របស់អង្គការខារ៉ាម្សមាន :

## ➲ ការបណ្តុះបណ្តាលមុនពេលចាកចេញ

អង្គការខារ៉ាមកម្ពុជាផ្តល់វគ្គបណ្តុះបណ្តាលពលករចំណាកស្រុកកម្ពុជាដែលត្រៀមខ្លួនចេញទៅធ្វើការងារនៅក្រៅប្រទេសដើម្បីធានាថាពួកគេទទួលបានសុវត្ថិភាពក្នុងការធ្វើចំណាកស្រុក ។





## ➲ កម្មវិធីបង្ការ ថែទាំ និងសិទ្ធិតាមសហគមន៍

អង្គការខារ៉ាមកម្ពុជា ផ្តល់វគ្គអប់រំដល់ស្ត្រីដែលធ្វើការងារតាមសេវាកំសាន្តនានា និង កម្មករសំណង់ក្នុងទីក្រុងភ្នំពេញ ស្តីពីមេរោគអេដស៍/ជំងឺអេដស៍ សុខភាពបន្តពូជ សិទ្ធិមនុស្សជាមូលដ្ឋាន ដើម្បីកាត់បន្ថយការឆ្លងរីករាលដាលនៃជំងឺកាមរោគ/ជំងឺអេដស៍ និងធានាអោយពួកគេទទួលបាននូវសេវាសង្គម ។





## ➲ កម្មវិធីស្រាវជ្រាវបែបចូលរួម

អង្គការខារ៉ាមកម្ពុជា ធ្វើការសិក្សាស្រាវជ្រាវដើម្បី កំណត់ពីបញ្ហាប្រឈមមុខរបស់ពលករចំណាកស្រុក ក្នុងគោលបំណងរៀបចំកម្មវិធីអន្តរាគមន៍ និង ការទាក់ទាញមតិគាំទ្រ ដើម្បីអោយមានការផ្លាស់ប្តូរជាវិជ្ជមាននូវស្ថានភាពពលករចំណាកស្រុក ។

## ➲ ការសម្របសម្រួលថ្នាក់តំបន់

អង្គការខារ៉ាមកម្ពុជា បានធ្វើការលើកកំពស់ និងការពារសិទ្ធិពលករចំណាកស្រុក ដោយសហការជាមួយនឹងបណ្តាញថ្នាក់តំបន់ដើម្បីរៀបចំកិច្ចពិគ្រោះយោបល់ សិក្ខាសាលា សន្និសីទការសែតផ្សេងៗ និងចែករំលែកពត៌មានស្តីពីស្ថានភាពពលករចំណាកស្រុក ។




## ➲ ការធ្វើមាតុភូមិនិវត្តន៍ និងការគាំទ្រ

អង្គការខារ៉ាមកម្ពុជា ធ្វើមាតុភូមិនិវត្តន៍ជនរងគ្រោះដោយការជួញដូរមនុស្ស និងកំលាំងការងារមកប្រទេសកំណើតវិញ និង សម្របសម្រួលធ្វើសមាហរណកម្មបញ្ជូនជនរងគ្រោះទៅសហគមន៍ ដើម្បីស្តារយុវនីតិសម្បទារបស់ពួកគេឡើងវិញ ។

## ➲ ការផ្តល់ជំនួយផ្លូវច្បាប់ចំពោះពលករចំណាកស្រុក

ដើម្បីលើកកំពស់និងការពារសិទ្ធិពលករចំណាកស្រុក អង្គការខារ៉ាមកម្ពុជា សម្របសម្រួលក្នុងការផ្តល់ជំនួយផ្លូវច្បាប់ដល់ពលករចំណាកស្រុក ដើម្បីធានាថាពួកគេទទួលបាននូវសេវាផ្លូវច្បាប់ និង យុត្តិធម៌ ។







## ➲ ការទាក់ទាញមតិគាំទ្រ និងភាពជាដៃគូ

ដើម្បីផ្លាស់ប្តូរជាវិជ្ជមាននូវស្ថានភាពពលករចំណាកស្រុកអង្គការខារ៉ាមកម្ពុជាបានរៀបចំ សកម្មភាពទាក់ទាញមតិគាំទ្រនានាដូចជា ទិវាជនចំណាកស្រុកអន្តរជាតិ កម្មវិធីជជែកពិភាក្សាតាមវិទ្យុ ទូរទស្សន៍ វេទិកាសាធារណៈ សន្និសីទកាសែត និងសេចក្តីថ្លែងការណ៍ផ្សេងៗ ។



